# សិលាចារឹកទួលវត្តចាស់ ឬវត្តពោធិអំពិល (K.1460)

ទួលវត្តចាស់ ជាបុរាណដ្ឋានសម័យមុនអង្គរមួយកន្លែង ដែលមានទីតាំងស្ថិតនៅភូមិពោធិ ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ។ នៅទីនេះ គេធ្លាប់រកឃើញសិលាចារឹកចំនួន ៣ ផ្ទាំង ជាប្រភេទគោលចារឹក។ ក្រោយមក គេបានយកសិលាចារឹកទាំងបីផ្ទាំងនេះ ទៅរក្សាទុកនៅវត្តពោធិអំពិល ដែលមានចម្ងាយពីទួលវត្តចាស់ត្រឹមតែ ១០០០ ម៉ែត្រប៉ុណ្ណោះ។ ក្នុងនោះ គោលចារឹកទី១ មានចារឹកអក្សរចំនួន ២៥ បន្ទាត់, គោលចារឹកទី២ មានអក្សរចំនួន ៣០ បន្ទាត់ និងគោលចារឹកទី៣ មានអក្សរចំនួន ៣ បន្ទាត់។ នៅក្នុងអត្ថបទនេះ ខ្ញុំសូមជ្រើសរើសតែគោលចារឹកទី១មកសិក្សាប៉ុណ្ណោះ។ តើសិលាចារឹកទួលវត្តចាស់ ឬវត្តពោធិអំពិល (គោលចារឹកទី១) លេខបញ្ជី K.1460 មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្ដេចខ្លះ?

ដូចបានបញ្ជាក់ខាងលើ គោលចារឹកទី១ មានអក្សរចារឹកសរុបចំនួន ២៥ បន្ទាត់ ដែលជាសំណេរនៅក្នុងស.វ.ទី៧ (គ.ស.៦២៥)។ ក្នុងនោះ សំណេរជាភាសាសំស្រ្កឹតនៅផ្នែកខាងលើ មានចំនួន ១១ បន្ទាត់ (ស្មើនឹង ១០ ស្លោក) និងអត្ថបទសំណេរជាភាសាខ្មែរបុរាណនៅផ្នែកខាងក្រោម មានចំនួន ១៤ បន្ទាត់ (ចាប់ពីបន្ទាត់ទី១២)។ គួរកត់សម្គាល់បំផុត គឺសិលាចារឹកនេះរៀបរាប់អំពីព្រឹត្តិការណ៍របស់ព្រះបាទស្រីភវវរ្ម័ទី២ (ត្រូវជាបុត្ររបស់ព្រះបាទស្រីសានវរ្ម័ទី១) ព្រោះសិលាចារឹកដែលរៀបរាប់អំពីទ្រង់មានចំនួនតិចតួចខ្លាំងណាស់។ ទោះបីជាសិលាចារឹកនេះ មិនបានផ្ដល់ន័យពេញលេញអំពីទ្រង់ក៏ពិតមែន ប៉ុន្តែវាជាទិន្នន័យរួមផ្សំមួយដែលនាំឱ្យគេដឹងថា នៅតំបន់ដែលបានរកឃើញសិលាចារឹកនេះ (ស្រុកទ្រាំង) ជាដែនដីឯកភាពជាតិបន្តអំពីព្រះបិតា (ព្រះបាទស្រីសានវរ្ម័ទី១) របស់ទ្រង់។

សិលាចារឹកនេះ ចារឹកឡើងដោយមន្ត្រីម្នាក់របស់ព្រះបាទស្រីភវវរ្ម័ទី២ ក្នុងពេលដែលលោកមកកសាង និងអភិវឌ្ឍទេវស្ថាន។ ប៉ុន្តែ មន្ត្រីរូបនេះបានសម្ដែងសេចក្ដីគោរពដល់ព្រះរាជាយ៉ាងខ្លាំង ដោយបានរំលេចព្រះនាមរបស់ព្រះរាជានៅខាងដើមជាមុនសិន ទើបបញ្ជាក់ដល់ម្ចាស់អំណោយ ឬនាមរបស់មន្ត្រីខាងក្រោយ។ ក្នុងនោះ ស្លោកទី១ បានបាក់បែកនៅផ្នែកខាងលើ ហើយអ្វីដែលនៅសល់មិនអាចកាត់ន័យយល់បាន ប៉ុន្តែ ទំនងជាស្លោកនមស្ការចំពោះទេពក្នុងសាសនាហិណ្ឌូ។ ស្លោកទី២ និងទី៣ ពណ៌នាបញ្ជាក់អំពីព្រះនាមព្រះបាទស្រីភវវរ្ម័ទី២ ក្នុងឋានៈជាស្ដេចអធិរាជ ឬស្ដេចផែនដី។ ស្លោកទី៣ ដល់ទី៦ ពណ៌នាអំពីគុណសម្បត្តិព្រះរាជា និងគុណសម្បត្តិរបស់មន្ត្រី។ ស្លោកទី៧ ពណ៌នាអំពីការប្រតិស្ឋានព្រះសិវលិង្គ។ ស្លោកទី៨ ពណ៌នាអំពីឆ្នាំ

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់

*នៃការប្រតិស្ឋានព្រះសិវលិង្គនៅក្នុងមហាសករាជឆ្នាំ ៥៦៧ (ត្រូវនឹងគ.ស.៦៤៥)។ រីឯ ស្លោកទី៩ ដល់ទី១០ ពណ៌នាអំពីការធ្វើអំណោយចំពោះទេវស្ថាន និងបណ្ដាសា។*

*ដោយឡែក ចាប់ពីបន្ទាត់ទី១២ (ផ្នែកភាសាខ្មែរបុរាណ) ដល់ទី២៥ បានផ្ដល់ព័ត៌មានជាច្រើនអំពីម្ចាស់អំណោយទាន និងស្ថាននាមទីតាំងបុរាណនៅតំបន់នេះ។ ក្នុងនោះ ម្ចាស់ទានម្នាក់បានរៀបរាប់ឈ្មោះ គឺ "**ម្រតាញកុមារ**" និងម្ចាស់ទានម្នាក់ទៀតមិនបានរៀបរាប់ឈ្មោះនោះទេ ពោល គឺគ្រាន់តែបញ្ជាក់ថា "**ម្រតាញយជមាន**" ("យជមាន" ប្រែថា៖ ម្ចាស់ទាន)។ អំណោយមានជាដីធ្លី ដែលដីទាំងនោះមិនមែនជាកម្មសិទ្ធិរបស់គាត់នោះទេ គឺគាត់បានដាវពីបុគ្គលផ្សេងទៀត។ ក្នុងសិលាចារឹកបានបញ្ជាក់ដល់ឈ្មោះម្ចាស់ដីដែលបានដាវនោះ រួមមានដូចជា បោញជយវម្ម៌, បោញទេវភិនវស្វាអញ, បោញអក្សរ និងព្រមទាំងទីតាំងដី។ អ្វីដែលគួរឱ្យកត់សម្គាល់ គឺមានឈ្មោះថា "**បោញជយវម្ម៌**" ដែលជាព្រះនាមដូចទៅនឹង "ព្រះបាទស្រីជយវម្ម៌ទី១" ប៉ុន្តែ មានឋានន្តរនាមថា "បោញ" ដែលនាំឱ្យយើងដឹងថាបុគ្គលនេះមិនមែនជាព្រះមហាក្សត្រនោះទេ។ ទោះបីជាយ៉ាងណា តើបុគ្គលឈ្មោះ "បោញជយវម្ម៌" នេះ អាចជាអនាគតព្រះបាទស្រីជយវម្ម៌ទី១ ដែរឬទេ? តើនាមនេះ អាចជានាមមុនឡើងគ្រងរាជ្យសម្បត្តិរបស់ព្រះបាទស្រីជយវម្ម៌ទី១ ដែរឬទេ? នេះគ្រាន់តែជាការលើកជាសំណួរមកពិភាក្សាតែប៉ុណ្ណោះ ដ្បិតយើងមិនមានភស្តុតាងណាមួយធ្វើជាអំណះអំណាងឱ្យបានជាក់លាក់នោះឡើយ ពោល គឺមានតែរង់ចាំព័ត៌មានបន្ថែម និងការស្រាវជ្រាវបន្ថែមទៀតនៅពេលក្រោយតែប៉ុណ្ណោះ។ បន្ថែមពីព័ត៌មានដែលបានរៀបរាប់ខាងលើ ទិន្នន័យពីផ្នែកភាសាខ្មែរបុរាណនៃសិលាចារឹកនេះ បាននាំឱ្យយើងដឹងថា ដីធ្លីភូមិករ និងទាសាទាសី (អ្នកបម្រើ) ស្រែចម្ការ ដែលបានដាវទាំងនេះ បានថ្វាយដល់ទេវស្ថាន ដើម្បីជាមូលនិធិសម្រាប់ទ្រទ្រង់ទេវស្ថាន។ ម្យ៉ាងវិញទៀត យោងតាមខ្លឹមសារផ្នែកភាសាខ្មែរនៃសិលាចារឹកនេះ យើងបានស្គាល់ស្ថាននាម (នាមទីតាំង) ជាច្រើនកន្លែង ដូចជា ស្រែស្តុកបោយោង, ជ្រៃវា, សង្វរលោម, ធ្វី, ស្តុកចោង, ស្រែថ្ងៃកើតក្រោម (ខាងកើត), ស្រែត្រពាំងបោកុមារ, ស្រែដើម, ស្រែត្រើយ, ជើងស្រុក និងត្រពាំងម្រតាញ។*

## **អត្ថបទចារឹក**

| | | |
|---|---|---|
| ១. | .........................ហជា | ជណិតាចាក.................. |
| | ............................... | ......................................។ |
| ២. | .............ត្រីករវម្មាស្ដិ | លោកោប្តាស្យាជយីករ...... |

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

............................ ....................................។

៣. ....................តន្ទលិតោត្តុង្គ ស្ថាបវេធិចជាបិដាំ
ធិរាជសោ....................... ...................................។

៤. ...ន្ត្រិតិក្សីតិបតៅរក្សត្យក្សតរក្សណោ តបស្វិ ស្វៃមិកិស្វៅ...............
...កីត្តិកុំណៃហ្គ័ទ្រែះកីត្តិតះកីត្តិកីត្តិតៃ អចាស្តាកីត្តិសកីត្តិទ្ធិក្សតីត្យ

៥. ..ណាជ្រិ្សបត្រមោឆ្យុក្វា ដម្នាំថ៌ដលតោមិតះ
កុណិដាមត្រកាមីម្ភះ ច្រាយោជ្យោ.........។

៦. ..............ង្គារសញ្ជូរិ ហិជ្រិ្សចារាប្រចារិតស្ថាន
កក្តិកុណាទ្រវៃ្យរ ដៃមម្យេវិជិត....។

៧. ...ទលិង្គ័មិកស្យ សរិទ្ធ្យយមតិម្វិបតិ
មហីយាត្តៅរស្សត្ត៌ វាសស្ទេយាន្តវេធិតិ។

៨. ..លិង្គ័ស្យស្ថាបដាស្យាសិថ ឆកោទ្រ្វស្សទ្រិឆម្វរ
កុចេន្ទ្រ័វឡាទយុ្គម.. កាឡាកតិយជា។

៩. ...អស្មៃកោក្សេត្រជាសាធិ កឌ្វកេយ៌្យាធិចក្សមិ
ទ្រវ្យកុទ្ធាគមោបេត សោយវ្យតរជាជ្វីរី។

១០. ...ឯរំ សវ៌្វមិធំឧត្តមិ វិជាយេឯកោដំចិតិ
ហម្វតវាក្សេកិតម្វាបិ សយាន្វក្វេយសាបឌ។

១២. *អំនោយ៑ ម្រតាញ៑យជមាន ទោង៑ម្រតាញ៑កុមារ អាយ៑តវ្រះកម្រតាញ៑*

១៣. *អញ៑ស្រេអាយ៑ស្តុក៑បោយោង៑អំវីតគិ្ ជ្រៃវាសង្វ៑រលោមិតគិ្ធ្វីស្តុក៑ចោង៑មនិ*

១៤. *ជាហ្វ៑តបោញ៑ជយវម៌្មបោញ៑ទេវាកិនវស្យា អញ៑ បោញ៑អក្សរ គេសនិប្រទានគិ្ ត*

១៥. *វ្រះឧក្កអំរុង៑គិ្សរេពស្រេតោ្វកេតិករាំស្រេមនិជាហ្វ៑តបោញ៑ជានគិ...មាសិ*

១៦. *ស្រេអាយ៑ត្រវង៑បោកុមារិមនិជាហ្វ៑តបោញ៑គង្គ៑រទោង៑តាង៑អំបេលិមោយ៑ ...*

១៧. *ទ៑ស្រេអាយ៑តំ ..................................*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

AMS អរិយធម៌ខ្មែរ

១៨. អាយិកញ្ចិតនៃ ..ព្រៅបោញដោនិសុរេ២ស្រេត្រេយអំរីដេង៍ស្រុក

១៩. .. ល្វបិត្រវង៍ម្រតាញ....ត្រវង៍ម្រតាញ...មតី ....

២០. ..លោហិត្រវង៍ .....លោហិត្រវង៍បោញវាបិទនិលោហអំរុង៍

២១. ...វ្យអាយិតស្រេ...... ស្រុកអំរីតគិ្ជុំត្រវង៍អាយ ...រិ .........

២២. .. វ្រះសិង៍ក្ញុំវ្រះ ....វា ...យិ ...វាត្មរិវាជោ...កវាកញ្ចតិវា..

២៣. ..រិវាក្មសិវាសុទាសិវាសុចិតវាក្មេបិវាបពោយិវាក្មតិក្ញុំត

២៤. ....តបិកោនិកុ... កុតតិកោនិកុ៤កុទិទ្វាមតិកោនិកុ១ប្រិ..

២៥. ..កោនិកុ ...កុកន្ទីនិកុអនោតិកុគុ......មនី๏

## សេចក្តីប្រែ

១. .........................ហទា ផណិតាបាក..................

.................................. ......................................។

២. ...ព្រះបាទ **ស្រីភវវរ្ម័** ទ្រង់មានវត្តមាន... ទ្រង់ញ៉ាំងលោកទាំងមូលឱ្យភ្លឺស្វាងដោយរស្មីនៃព្រះហស្ត (ឬដោយការដាក់ទាន)..។

៣. ...ការប្រតិស្ឋានទូវវេទិកា (អាសនៈ) ដ៏ខ្ពង់ខ្ពស់... ជាអធិរាជ...

៤. ក្នុងពេលដែលព្រះរាជាម្ចាស់ផែនដី កំពុងគ្រប់គ្រងរក្សាការពារផែនដីដោយមិនឱ្យមានការអន្តរាយ... លោក (មន្ត្រី) ជាអ្នកដឹងនូវតបធម៌... ជាអ្នកមានមន្តលដោយសារគុណសម្បត្តិឱ្យមានគុណសម្បត្តិនៃកេរ្តិ៍ឈ្មោះ ដែលត្រូវបានគេពោលសរសើរ (កីត៌ិត) សាយភាយទៅសព្វទិសទី និងបានកម្ចាត់ចោលនូវអកេរ្តិ៍ឈ្មោះ (សេចក្តីអាក្រក់) ទាំងពួង។

៥. ...ដោយសេចក្តីព្យាយាមបម្រើនៅក្បែរព្រះបាទ (នៃព្រះរាជា).... យល់ដឹងនូវផលនៃធម៌ និងផលនៃទ្រព្យសម្បត្តិ (ធម៌-អថ៌) .... លោក គឺជាអ្នកឈានមុខគេក្នុងចំណោមអ្នកមានគុណធម៌។

៦. ....ទោះបីជាទឹកទន្លេនោះពោរពេញដោយសត្វសាហាវ (ហិង្រ្ស) ដើរចុះឡើង... ក៏លោកបានយកឈ្នះលើឧបសគ្គទាំងឡាយ ដោយសារអំណាច (សក្តិ) គុណសម្បត្តិ និងរួមទាំងទ្រព្យសម្បត្តិ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់

៧. .... (លោក) អ្នកមានវិជ្ជាខ្ពង់ខ្ពស់ បានប្រតិស្ឋានទូវលិង្គ (សិវលិង្គ) នៃព្រះមហេស្វរ (ព្រះសិវ) .... ដើម្បីទទួលបាននូវការស្នាក់នៅស្ថានសួគ៌ដ៏ខ្ពង់ខ្ពស់។

៨. ការប្រតិស្ឋានរូបលិង្គនេះ បានធ្វើឡើងនៅក្នុងមហាសករាជឆ្នាំ ៩៦៧ (អទ្រិឆម្ភរ គឺអទ្រិ=៧, បដី=៦, គរ=៩) ក្នុងខែជេស្ឋ (គុចិ) ថ្ងៃទី៩ (នវ) ខ្នើត ក្នុងពេលដែលព្រះចន្ទស្ថិតនៅក្នុងរាសីកញ្ញា។

៩. លោកដែលជាអ្នកមានសេចក្តីស្មោះត្រង់ និងមានចិត្តស្ងប់ បានថ្វាយចំពោះព្រះជាម្ចាស់ (ព្រះសិវ) នូវទ្រព្យសម្បត្តិ រួមមាន ហ្វូងគោ ស្រែចម្ការ ខ្ញុំបម្រើ ព្រមទាំងគ្រឿងតន្ត្រី រួមមានស័ង្ខ និងភេរី ជាដើម។

១០. រាល់ទ្រព្យសម្បត្តិទាំងអស់ដែលបានផ្តល់ឱ្យហើយ ប្រសិនបើមានបុគ្គលណាម្នាក់មកដណ្តើមយក ឬមកបំពាន សូមឱ្យបុគ្គលនោះ ព្រមទាំងញាតិសន្តាន ធ្លាក់ទៅក្នុងសេចក្តីវិនាស និងគ្រោះថ្នាក់។

**(សេចក្តីប្រែផ្នែកភាសាខ្មែរ)**

(បន្ទាត់ទី១២ ដល់២៩). អំណោយរបស់ម្រតាញយជនមាន រួមជាមួយនិងម្រតាញកុមារអញ៖ ស្រែនៅស្តុកបោយោង អំពី ជ្រៃវា សន្ធរលោម ដែលគឺជា ធ្វី ស្តុកចោង ដែលបានជាវអំពីបោញជយវម្ម៌, បោញទេវកិនវង្ស, អញ, បោញអក្សរ បានប្រមូលរួមគ្នាប្រទានដល់ព្រះជាម្ចាស់ក្នុងទំហំ ៧ សរេ។ ស្រែថ្ងៃកើត (ទិសខាងកើត) ក្រោម ស្រែជាវពីបោញជាន គិ....មាស។ ស្រែនៅត្រពាំងបោកុមារ ស្រែជាវពីបោញគន្ធរ ព្រមទាំងតាងអំបិលមោយ....។ ស្រែនៅដើម.......ស្រែ នៅកញ្ចិត...ព្រៃ បោញជាន ២ សរេ។ ស្រែត្រើយ រាប់អំពីជើងស្រុក ..... ល្វប ត្រពាំង ម្រតាញ .... ត្រពាំង ម្រតាញ....មតី....លោហត្រពាំង ...... លោហត្រពាំង បោញវាបទនលោហអំរុង....ពីរស្រែ ... ស្រុកអំពី គឺជុំត្រពាំង....ព្រះ ខ្ញុំព្រះ (អ្នកបម្រើ) ....រួមមាន៖ វា ..... យ ...., វា ត្មុរ, វាដោ...ក, វាកញ្ចត, វា....រិ, វាក្ញស, វាសុទាស, វាសុចិត, វាក្ទេប, វាបរោយ, វាក្នត, ក្ញុំ ត....តចកូន កុ..., កុតត, កូន ៤, កុទិទ្នាមតិ កូន១ ប្រិ....កូន, កុ..., កុកន្ទីន, កុអនោត, កុគុ....មនី០។

សរុបជារួមមក សិលាចារឹកទួលវត្តចាស់ ឬវត្តពោធិអំពិល (គោលចារឹកទី១) K.1460 បានផ្តល់នូវទិន្នន័យប្រវត្តិសាស្ត្រយ៉ាងសំខាន់នៅសម័យមុនអង្គរ (ស.វ.ទី៧)។ ថ្វីត្បិតតែសិលាចារឹកនេះមានការខូចខាតខ្លះៗក៏ដោយ ប៉ុន្តែខ្លឹមសារដែលនៅសេសសល់បានបង្ហាញយ៉ាងច្បាស់អំពីទិដ្ឋភាពនយោបាយ និងការគ្រប់គ្រងដែនដី ជាពិសេស គឺបានជួយបញ្ជាក់អំពីអត្ថិភាព និង

អំណាចរដ្ឋបាលរបស់ព្រះបាទស្រីករវម៌្មទី២ នៅក្នុងតំបន់ស្រុកទ្រាំង ខេត្តតាកែវ ដែលបង្ហាញថា តំបន់នេះ ជាដែនដីស្ថិតក្រោមការគ្រប់គ្រងឯកភាពជាតិបន្តពីព្រះបិតារបស់ទ្រង់ (ព្រះបាទស្រីសានវម៌្មទី១)។ ក្នុងនោះ ខ្លឹមសារសិលាចារឹកនេះ ក៏បានបញ្ជាក់អំពីជំនឿសាសនា និងសទ្ធាជ្រះថ្លារបស់ម្ចាស់អំណោយទាន ពោល គឺផ្នែកភាសាសំស្ក្រឹតបានបង្ហាញពីការគោរពបូជាយ៉ាងខ្ពង់ខ្ពស់ចំពោះព្រះសិវ និងការប្រតិស្ឋានព្រះសិវលិង្គនៅក្នុងម.ស.៥៦៧ (ត្រូវនឹងគ.ស.៦៤៥) ដោយមានការចូលរួមពីមន្ត្រីជាន់ខ្ពស់របស់ព្រះរាជា។ ដោយឡែក នៅក្នុងផ្នែកភាសាខ្មែរ បានផ្តល់ព័ត៌មានឱ្យដឹងអំពីប្រព័ន្ធសេដ្ឋកិច្ចសង្គម តាមរយៈការដោះដូរទិញលក់ដីធ្លី ការថ្វាយដីស្រែ ភូមិករ ព្រមទាំងអ្នកបម្រើ (ខ្ញុំបម្រើ) ដល់ទេវស្ថាន ដើម្បីបង្កើតជាមូលនិធិទ្រទ្រង់សាសនដ្ឋានឱ្យមានស្ថិរភាពយូរអង្វែង។

អត្ថបទដោយ៖ កំ វណ្ណាក់ និងព្រះតេជគុណ អេង សុគង់



រូបលេខ១៖ ទីតាំងតម្កល់សិលាចារឹកទួលវត្តចាស់បច្ចុប្បន្ន (នៅក្នុងបរិវេណវត្តពោធិអំពិល)



រូបលេខ២៖ សិលាចារឹកទួលវត្តចាស់ ឬវត្តពោធិអំពិល K.1460

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ៣៖ សំណៅផ្តិតសិលាចារឹកទួលវត្តចាស់ ឬវត្តពោធិអំពិល K.1460
(ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់